

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៦...ស.ជ.... ...

សារាចរ

ស្តីពី

ការទប់ស្កាត់រំពើអនាធិបតេយ្យ

នៅតំបន់សៀមរាប-អង្គរ

កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាមានរមាទនភាព ដោយបានទទួលការកោតសរសើរពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ចំពោះឆន្ទៈនិងការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយស្តីពីការអភិរក្សនិងការអភិវឌ្ឍតំបន់សៀមរាប-អង្គរ ។ ជារួម យើងបានលុបបំបាត់ចោលនូវការបំផ្លិចបំផ្លាញ ការលុចសម្បត្តិវប្បធម៌ស្ទើរតែទាំងអស់ពីតំរង់អង្គរ បានធ្វើការដោះទ្រម្រង់និងជួសជុលប្រាសាទដែលទ្រុឌទ្រោមមួយចំនួន ការពារប្រាសាទនិងបរិស្ថានបានប្រសើរឡើង ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមួយចំនួនសំរាប់ភ្ញៀវទេសចរ និង ធានាបានទាំងស្រុងនូវសុខសុវត្ថិភាពដល់បងប្អូនប្រជាពលរដ្ឋក៏ដូចភ្ញៀវទេសចរ ពោលគឺ យើងបានដុះលើការ ការពារ អភិរក្សប្រាសាទផង និងអភិវឌ្ឍតំបន់អង្គរជុំវិញការរីកចំរើនខាងវិស័យទេសចរណ៍ ព្រោះថាអង្គរជាបេះដូងនៃការអភិវឌ្ឍទេសចរណ៍វប្បធម៌កម្ពុជា ។

ប៉ុន្តែរយៈពេលចុងក្រោយនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតំបន់សៀមរាប-អង្គរ ក៏មានការកើតឡើងវិញនូវ ភាពអនាធិបតេយ្យតូចឱ្យធ្ងន់ធ្ងរដែរ ដែលបង្កឡើងដោយក្រុមជនមួយចំនួនតូច បណ្តាលឱ្យមានការប៉ះពាល់ដល់ដំណើរការ ការពារ និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់រមណីយដ្ឋាន សៀមរាប-អង្គរ ។

ភាពអនាធិបតេយ្យទាំងនោះរួមមាន ការលួចនិងការប៉ង្កាញ់វត្ថុបុរាណ ការតាប់ព្រៃទន្ទ្រានយកដី ការរំលោភយកដីធ្លីជាកម្មសិទ្ធិ ការប្រកាសផ្សាយទិញលក់ដី និង ការកាំងអូបលក់ដូរក្នុងតំបន់ហាមឃាត់ ការសាងសង់សំណង់ផ្សេងៗនៅក្នុងរមណីយដ្ឋានអង្គរ ដែលជាតំបន់ត្រូវបានរក្សាទុកនិងត្រូវបានការពារដោយច្បាប់ ។

ដើម្បីទប់ស្កាត់នូវអំពើអនាធិបតេយ្យខាងលើ ជាពិសេសក្នុងគោលដៅបន្តការការពារថែរក្សាសម្បត្តិវប្បធម៌ជាតិ និងពិភពលោកនៅអង្គរ ដែលជាអចលនទ្រព្យសម្បត្តិរដ្ឋ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

១. រាជធានីខេត្តអប្សរា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀតដល់ប្រជាពលរដ្ឋ នូវព្រះរាជក្រឹត្យ លេខ ០០១ នស.ជ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៤ ស្តីពីការតំណាត់ និង ការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ

និងត្រូវសហការជាមួយកងកម្លាំងមានសមត្ថកិច្ច និង អាជ្ញាធរមូលដ្ឋាន ដើម្បីចាត់វិធានការការពារសម្បត្តិវប្បធម៌ជាតិ និងធម្មជាតិឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ចំពោះអណ្តូកម្មការចម្រុះ ស្តីពីការទប់ស្កាត់អំពើអនាធិបតេយ្យក្នុងឧទ្យានអង្គរ ដែលបានបង្កើតឡើងតាមដីកាសាលាខេត្តសៀមរាបលេខ ០១៨ សសរ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលតាមរយៈអាជ្ញាធរអប្សរា នូវការវិវត្តក្នុងតំបន់នោះជារៀងរាល់ខែ ។

២. ក្រសួងការពារជាតិ និង អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ត្រូវចេញបទបញ្ជាដល់អង្គភាព ដែលឈរជើងនៅទីនោះ ឱ្យជួយទប់ស្កាត់អំពើអនាធិបតេយ្យខាងលើ ។

៣. ក្រសួងមហាផ្ទៃ និង អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវធ្វើការណែនាំជាបន្ទាន់ដល់អាជ្ញាធរដែនដី និងកងកម្លាំងនគរបាលប្រចាំការនៅមូលដ្ឋាន ឱ្យបង្កើនការយកចិត្តទុកដាក់ខ្ពស់ដល់ការការពារសន្តិសុខសណ្តាប់ធ្នាប់ ការការពារបេតិកភណ្ឌជាតិ សុវត្ថិភាពដល់ភ្ញៀវទេសចរ និងធ្វើការណែនាំដល់ប្រជាពលរដ្ឋដើម្បីបញ្ឈប់ការកាប់ព្រៃ ទន្ទ្រានយកដីមកធ្វើជាកម្មសិទ្ធិ និងឱ្យជួយចូលរួមសហការការពារសម្បត្តិវប្បធម៌ជាតិ និងធម្មជាតិ នៅតំបន់ស្ទើរអាច-អង្គរ ។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន ត្រូវធ្វើការណែនាំដល់មន្ត្រីក្រោមឱវាទ ដោយសហការជាមួយ អាជ្ញាធរអប្សរា កម្លាំងមានសមត្ថកិច្ច និង អាជ្ញាធរដែនដី ដើម្បីបង្កើនការការពារឱ្យបានម៉ឺងម៉ាត់ជាទីបំផុតនៅតំបន់នោះ។

ទទួលបានសារាចរនេះ ត្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអប្សរា អាជ្ញាធរដែនដី ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០០៣

ហ៊ុន សែន

ចម្លងជូន :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និង ខេត្ត-ក្រុង
-កាលប្បវត្តិ-ឯកសារ

លេខ: ១២.ស.ក.....ចល
ចានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ផ្ញើជូន :
- ឯកឧត្តមមេបញ្ជាការយោធភូមិភាគទី ៤
- លោកមេបញ្ជាការកងកំលាំងប្រដាប់អាវុធខេត្តសៀមរាប
សូមជូនជ្រាប និងមូលការ
- គ្រប់មន្ទីរអង្គភាពក្នុងខេត្ត
- គ្រប់ស្រុក
- គ្រប់ឃុំ
ដើម្បីផ្សព្វផ្សាយ និងអនុវត្ត
សៀមរាប ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៣
ជ.រកិបាលខេត្ត តប.
អាយុខុទ្ទកាល័យ